STABLU
SCI-TECH




# សៀវភៅណែនាំ

## IoE V.3.1

ឆ្នាំ២០២១

# ចំណុចត្រូវប្រុងប្រយ័ត្ន






# សេចក្ដីណែនាំទូទៅ




## មុខងារ និងតួនាទី៖

- **ឧបករណ៍ភ្ជាប់ភ្លើងសូឡា៖** សម្រាប់ភ្ជាប់ភ្លើងដែលបានផ្ដល់ពីសូឡា
- **និមិត្តសញ្ញាអាសន្ន៖** បង្ហាញពីអាសន្នដែលនឹងកើតឡើងចេញពីទូរ
- **និមិត្តសញ្ញាសាក៖** បង្ហាញពីការសាកថ្មពីសូឡា ថាតើសាកចូល ឬអត់
- **USB 5V 2A៖** ប្រើប្រាស់សម្រាប់សាកថ្មទូរស័ព្ទ
- **កុងតាក់អាំងវឺតទ័រ៖** តួនាទីដើម្បី បិទ/បើក អាំងវឺតទ័រក្នុងការប្រើប្រាស់

# សេចក្តីណែនាំទូទៅ




## មុខងារ និងតួនាទី៖

- **ព្រីទី ១៖** ត្រូវបានតភ្ជាប់ចេញពីទូរផ្ទាល់ ដើម្បីប្រើប្រាស់ជាមួយឧបករណ៍ដែលចាំបាច់ជាងគេ
- **ព្រីទី ២ និងទី ៣៖** សម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ដែលជាអាទិភាពបន្តបន្ទាប់ពីគ្នា
- **ព្រីបន្ទាប់បន្សំ៖** សម្រាប់ប្រើប្រាស់នៅពេលសូឡាផលិតភ្លើងលើសពីថ្មអាចផ្ទុកបាន
- **កន្លែងដាក់ទូរស័ព្ទ៖** អាចប្រើប្រាស់សម្រាប់ដាក់ទូរស័ព្ទនៅពេលសាកចេញពីទូរ

# សេចក្តីណែនាំទូទៅ


ឌីសុងទ័រ
AC
ទុយស៊ីប
15A
ប្រព័ន្ធឆ្លាតវៃ
IoE
កុងត្រូល័រ
ឌីសុងទ័រ
DC
ប្រអប់
ប្រសព្វភ្លើង
ថ្ម
អាំងវើតទ័រ
PowMr
Fuses 15A
IoE Powerwall V.3.1

## មុខងារ និងតួនាទី៖

- កុងត្រូល័រ៖
- ឌីសុងទ័រ **DC**៖
- ឌីសុងទ័រ **AC**៖
- ភុយស៊ីប **15A**៖
- ប្រព័ន្ធឆ្លាតវៃ **IoE**៖
- ប្រអប់ប្រសព្វភ្លើង៖
- ថ្ម៖
- អាំងវឺតទ័រ៖

# <u>ការគ្រប់គ្រង និងបញ្ជាតាមទូរស័ព្ទ</u>




## <u>ការប្រើប្រាស់៖</u>

- **ព័ត៌មានថ្ម៖** បង្ហាញពី តង់ស្យុងថ្ម ភាគរយថ្ម និងកម្ដៅក្នុងទូរនៅពេលប្រើប្រាស់ប្រចាំថ្ងៃ

# ការគ្រប់គ្រង និងបញ្ជាតាមទូរស័ព្ទ




## ការប្រើប្រាស់៖

- **ព័ត៌មានទូទៅ៖** បង្ហាញពី អានុភាពសរុបរបស់គ្រឿងទទួលដែលយើងបានប្រើប្រាស់ និងបង្ហាញពីអានុភាពដែលសូឡា ផលិតបាន
- **ការប្រើប្រាស់ថ្ងៃនេះ៖** បង្ហាញពីថាមពលដែលបានប្រើប្រាស់ និងថាមពលដែលសូឡាផលិតបានប្រចាំថ្ងៃ

# ការគ្រប់គ្រង និងបញ្ជាតាមទូរស័ព្ទ




## ការប្រើប្រាស់៖

- **ការប្រើប្រាស់ប្រចាំខែ៖** បង្ហាញពី ថាមពលដែលបានប្រើប្រាស់ និងថាមពលដែលសូឡាផលិតបានប្រចាំខែ
- **ការបង់ប្រាក់៖** បង្ហាញពីការចំណាយ នៃការប្រើប្រាស់ភ្លើងសរុប ប្រចាំថ្ងៃ និងប្រចាំខែ ថាតើត្រូវបង់ប្រាក់ប៉ុន្មានមកកាន់ **STABLU**

# ការគ្រប់គ្រង និងបញ្ជាតាមទូរស័ព្ទ




## ការប្រើប្រាស់៖

- **ការបញ្ជាឧបករណ៍៖** សម្រាប់ធ្វើការបញ្ជា បិទ/បើក ទៅកាន់ឧបករណ៍នីមួយៗដែលបានកំណត់ជាអាទិភាព។ ឧទាហរណ៍ "អាទិភាព១" ត្រូវបានកំណត់ជា "អំពូល" ដូច្នេះយើងអាចធ្វើការបញ្ជា បិទ/បើក អំពូលពីចម្ងាយតាមរយៈទូរស័ព្ទដៃ ឬកុំព្យូទ័របាន ដោយមិនចាំបាច់ទៅចុចបិទកុងតាក់ផ្ទាល់

# បញ្ហា និងដំណោះស្រាយ

## ❖ សន្សំសំចៃថាមពល



**លក្ខណៈសម្គាល់៖**

1. អំពូលភ្លើងនៅក្រោម និមិត្តសញ្ញាអាសន្នទាំងបីភ្លឺ ហើយនិមិត្តសញ្ញាអាសន្នភ្លឺពណ៌បៃតង
2. និមិត្តសញ្ញាថ្មនៅសល់មួយកម្រិត និងភ្លឺពណ៌លឿងទុំ
3. ព្រីអាទិភាព ២ ៣ និងព្រីបន្ទាប់បន្សំអាចនឹងត្រូវបិទ

**ដំណោះស្រាយ៖**

ឧបករណ៍ IoE នៅដំណើរការជាធម្មតា។

# បញ្ហា និងដំណោះស្រាយ

## ❖ អស់ថ្ម



**លក្ខណៈសម្គាល់៖**

1. អំពូលភ្លើងនៅក្រោមនិមិត្តសញ្ញាអាសន្នទាំងបីភ្លឺ ហើយនិមិត្តិសញ្ញាអាសន្នភ្លឺពណ៌បៃតង
2. និមិត្តសញ្ញាថ្ម នៅសល់មួយកម្រិត និងភ្លឺពណ៌ក្រហម
3. អាំងវឺតទ័រ អាចនឹងត្រូវបានបិទ

**ដំណោះស្រាយ៖**

ឧបករណ៍ **IoE** នៅដំណើរការជាធម្មតា នៅពេលមានពន្លឺថ្ងៃនឹងសាកថ្មឡើងវិញ ហើយគ្រប់យ៉ាងនឹងដំណើរការជាធម្មតា។

# បញ្ហា និងដំណោះស្រាយ

## ❖ អាសន្នកម្រិត ១



**លក្ខណៈសម្គាល់៖**

1. អំពូលនៅក្រោមនិមិត្តសញ្ញាអាសន្ន ភ្លឺតែពណ៌ក្រហមមួយប៉ុណ្ណោះ ហើយនិមិត្តសញ្ញាអាសន្នភ្លឺឆ្លាស់ពណ៌ក្រហម និងខៀវ
2. និមិត្តសញ្ញាថ្ម នៅសល់មួយកម្រិត និងភ្លឺលោតៗពណ៌ក្រហម
3. មានសម្លេងរោទិ៍ ផ្តល់ដំណឹងអាសន្ន

**ដំណោះស្រាយ៖**

បញ្ហានេះកើតឡើង ដោយសារថាមពលថ្មនៅទាបជាងកម្រិត សុវត្ថភាពដែលអាចបណ្តាលអោយឧបករណ៍បិទដោយមិនបានគ្រោងទុកមុន ប៉ុន្តែជាទូទៅពេលស្ថិតក្នុងអាសន្នកម្រិត ១ ថ្មអាចនឹងត្រូវបានសាកឡើងវិញនៅពេលមានពន្លឺថ្ងៃ ហើយគ្រប់យ៉ាងនឹងដំណើរការជាធម្មតា។

# បញ្ហា និងដំណោះស្រាយ

## ❖ អាសន្នកម្រិត ២



**លក្ខណៈសម្គាល់៖**

1. អំពូលនៅក្រោមនិមិត្តសញ្ញាអាសន្នភ្លឺពណ៌ក្រហម និងពណ៌លឿង ហើយនិមិត្តសញ្ញាអាសន្ននឹងភ្លឺឆ្លាស់ពណ៌ក្រហម និងខៀវ
2. និមិត្តសញ្ញាថ្ម អាចភ្លឺពណ៌បៃតង ពណ៌លឿងទុំ ឬពណ៌ក្រហម
3. មានសម្លេងរោទិ៍ ផ្តល់ដំណឹងអាសន្ន

**ដំណោះស្រាយ៖**

បញ្ហានេះកើតឡើងដោយការប្រើប្រាស់លើសពីអានុភាពរបស់អាំងវឺតត័រ ឬលើសពីចរន្តសុវត្ថិភាពដែលបានកំណត់។ ជាទូទៅនៅពេលស្ថិតក្នុងអាសន្នកម្រិត ២ ឧបករណ៍បានផ្តាច់ចរន្ត ប្រើប្រាស់ រយៈពេល ៣០វិនាទី ដើម្បីអោយអ្នកប្រើអាចដកឧបករណ៍ប្រើប្រាស់ចេញ។ ក្រោយពី ៣០វិនាទី នោះគ្រប់យ៉ាងនឹងដំណើរការជាធម្មតា។

# បញ្ហា និងដំណោះស្រាយ

## ❖ អាសន្នកម្រិត ៣



**លក្ខណៈសម្គាល់៖**

1. អំពូលនៅក្រោមនិមិត្តសញ្ញាអាសន្នភ្លឺទាំងបី ហើយនិមិត្តសញ្ញាអាសន្នភ្លឺឆ្លាស់ពណ៌ក្រហម និងខៀវ
2. និមិត្តសញ្ញាថ្ម អាចភ្លឺពណ៌បៃតង ពណ៌លឿងទុំ ឬពណ៌ក្រហម
3. មានសម្លេងរោទិ៍ ផ្តល់ដំណឹងអាសន្ន

**ដំណោះស្រាយ៖**

បញ្ហានេះអាចកើតឡើងដោយសារកម្តៅក្នុងទូរ ឬកម្តៅថ្មលើសពី ៤៥ អង្សារសេ នៅពេលដែលកម្តៅខ្ពស់វាអាចប៉ះពាល់ដល់អាយុកាលប្រើប្រាស់របស់ថ្ម និងសមត្ថភាពប្រតិបត្តិការរបស់ឧបករណ៍ នៅពេលស្ថិតក្នុងអាសន្នកម្រិត ៣ អាំងវឺតទ័រត្រូវបានបិទរហូតដល់កម្តៅក្នុងទូរចុះទាបវិញ ហើយគ្រប់យ៉ាងនឹងបើកដំណើរការជាធម្មតាវិញ។

# បញ្ហា និងដំណោះស្រាយ

## ❖ បញ្ហាមិនអាចឆ្នាប់អ៊ីនធឺណែតបាន



**លក្ខណៈសម្គាល់៖**

1. និមិត្តសញ្ញាអាសន្ន និងថ្មមិនភ្លឺ
2. និមិត្តសញ្ញាសាក ភ្លឺពណ៌រាងស្វាយ
3. ស្ថិតក្នុងលក្ខណៈ ១ និង ២ រយៈពេលលើសពី ៥នាទី

**ដំណោះស្រាយ៖**

បញ្ហានេះអាចកើតឡើងដោយសារ ការភ្ជាប់ទៅកាន់អ៊ីនធឺណែតមានភាពរអាក់រអួល ឬបរាជ័យ។ នៅពេលស្ថិតនៅក្នុងបញ្ហានេះ ឧបករណ៍នឹងមិនដំណើរការ ហើយប្រព័ន្ធ **IoE** នឹងព្យាយាមដំណើរការឡើងវិញដោយខ្លួនឯង។ ប៉ុន្តែក្នុងករណីនៅតែស្ថិតក្នុងស្ថានភាពនេះរយៈពេល ១៥នាទី គឺត្រូវទាមទារការបើកដំណើរការឡើងវិញដោយអ្នកប្រើប្រាស់។ ដើម្បីបិទបើកប្រព័ន្ធឡើងវិញ ត្រូវធ្វើតាមជំហានដូចខាងក្រោម៖

1. បើកគម្របមុខរបស់ឧបករណ៍ដូចរូបខាងក្រោម
2. ចុចកុងតាក់ដូចរូបទៅលេខ 0 បន្ទាប់មកចុចទៅលេខ I វិញ
3. ប្រសិនជាគ្រប់យ៉ាងនៅតែមិនដំណើរការ សូមធ្វើការទំនាក់ទំនងមកាន់លេខ 078 347 050




“ចុចកុងតាក់ដូចរូបទៅលេខ 0 បន្ទាប់មកចុចទៅលេខ I វិញ”

# បញ្ហា និងដំណោះស្រាយ

## ❖ បញ្ហាប្រើលើសកម្រិតថ្ម



### លក្ខណៈសម្គាល់៖

1. អំពូលភ្លើងនិមិត្តសញ្ញាទាំងបី នៅគម្របមុខមិនភ្លឺ
2. វាលអំពូលភ្លើង និងអេក្រង់បង្ហាញទិន្នន័យនៅក្នុងទូរ មិនភ្លឺ

### ដំណោះស្រាយ៖

បញ្ហានេះកើតឡើង ដោយសារអ្នកប្រើប្រាស់ ប្រើឧបករណ៍ អគ្គិសនីហួសពីសមត្ថភាពរបស់ថ្ម អាចផ្គត់ផ្គង់បាន ហើយប្រព័ន្ធថ្ម ត្រូវបានបិទដើម្បីសុវត្ថិភាពអ្នកប្រើប្រាស់។ ប្រសិនបើស្ថិតក្នុងស្ថានភាពនេះ សូមធ្វើការទាក់ទងមកកាន់ក្រុមការងារដើម្បីធ្វើការប្រឹក្សាយោបល់។

សេវាកម្មទូទៅ: 093 263 454 / 096 960 4049
បច្ចេកទេសទូទៅ: 078 347 050 / 077 925 709

Email: info@stablu.net
Facebook Page: STABLU
(https://web.facebook.com/stabluscitech/about/?ref=page_internal)

**STABLU Office and Research & Development Laboratory**

ផ្ទះលេខ ២៥៦, ផ្លូវលេខ ១៥0z, សង្កាត់ ទឹកល្អក់ទី២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា.



រចនា និង អភិវឌ្ឍន៍ នៅប្រទេសកម្ពុជា
Design and Development by STABLU Sci-Tech in **Cambodia**